**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៣២/០១/២០១៣ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៣

**គោរពជូន**

**ឯកឧត្តមប្រធានតុលាការកំពូល**

**កម្មវត្ថុ :** ពាក្យបណ្តឹងចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១២ របស់លោកមេធាវី **កៅ ស៊ូផា** សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃស្មារតីលិខិតលេខ ១៩៦៩ សជណ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**យោង :** - លិខិតលេខ ៧៣/១៣តកក ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០១៣ របស់ឯកឧត្តមប្រធានតុលាការកំពូល ។

- លិខិតលេខ ១៤៧៤ រ.ប ៩២១/២០១៣ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៣ របស់ប្រធានសាលាដំបូងរាជធានីភ្នំពេញ ។

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រធានជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៣ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យពាក្យបណ្តឹងរបស់លោកមេធាវី **កៅ ស៊ូផា** រួចហើយ ។ សំណើសុំអន្តរាគមន៍របស់ឈ្មោះ **កែវ ជិន** ទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីកាន់កាប់ដីទំនាស់ទំហំ ២៤ម x ២៤ម ស្ថិតនៅភូមិជម្ពូវ័ន្ត សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ បានធ្វើឡើងក្រោយសាលដីកាស្ថាពរលេខ ១៤១ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៥ របស់តុលាការកំពូល ។ តាមបទប្បញ្ញត្តិនៃវាក្យខណ្ឌទី៣ មាត្រា ១២៨ ថ្មី ( មាត្រា ១០៩ ចាស់) នៃរដ្ឋធម្មនុញ្ញ "*អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង*" ។ សាលដីកាស្ថាពររបស់តុលាការកំពូល ត្រូវមានអានុភាពអនុវត្ត ។

សូមឯកឧត្តមប្រធានទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh